**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០២៧/០២/២០១១ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១១

**ជម្រាបមក**

**ឯកឧត្តម តុ វ៉ាន់ចាន់**

អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ២៣A សង្កាត់ព្រែកឯង ខណ្ឌមានជ័យ រាជធានីភ្នំពេញ

**កម្មវត្ថុ** : រឿងទាក់ទងនឹងសំណើសុំប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានសម្រេចទទួលស្គាល់លោក សាន សាង ជាបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រអាណត្តិទី ៤ របស់គណបក្ស សម រង្ស៊ី នៅមណ្ឌលតាកែវ ជំនួសរូបឯកឧត្តមផ្ទាល់

**យោង** : ពាក្យបណ្តឹងតវ៉ារបស់ឯកឧត្តម ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ក្នុងកិច្ចប្រជុំនាថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១១ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើសំណើរបស់ឯកឧត្តមរួចហើយ ។ ដោយយោងបទប្បញ្ញត្តិមាត្រា ២៦ មាត្រា ២៧ ថ្មី និង មាត្រា ២៩ ថ្មី នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា សំណើរបស់ឯកឧត្តមមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

សូមឯកឧត្តមទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**
**ប្រធាន**
**ឯក សំអុល**